# ព្រះរាជក្រឹត្យ

នស/រកត/០៨០៤/២៣៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-**

បង្កើតគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ ហៅកាត់ "គ.ជ.ប.អ"។

**មាត្រា ២ .-**

**គ.ជ.ប.អ** មានតួនាទីជាជំនួយការក្នុងការត្រួតពិនិត្យការរៀបចំនិងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានាសំរាប់ប្រជាជន។

**មាត្រា ៣ .-**

**គ.ជ.ប.អ** មានគោលដៅនាំទៅរកការផ្លាស់ប្តូរក្នុងនិន្នាការប្រជាជន ដើម្បីអោយទំហំ សមាសភាព និងរបាយប្រជាជនសមស្របជាមួយនឹងតំរូវការនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព សំរាប់ កាត់បន្ថយភាពក្រីក្រ និង ការធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវិតរស់នៅរបស់ប្រជាជនកម្ពុជា។

**មាត្រា ៤ .-**

សមាសភាពថ្នាក់ដឹកនាំនៃ **គ.ជ.ប.អ** រួមមានដូចខាងក្រោម ÷

| | |
|---|---|
| - ឥស្សរៈជនមួយរូប | ជាប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ពីររូប | ជាអនុប្រធាន |
| - ឥស្សរៈជនមួយរូប | ជាអនុប្រធាន |
| - ឥស្សរៈជនមួយរូប | ជាអនុប្រធានប្រចាំការ |
| - តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| - តំណាង ក្រសួងផែនការ | ជាសមាជិក |
| - តំណាង ក្រសួងបរិស្ថាន | ជាសមាជិក |
| - តំណាង ក្រសួងសុខាភិបាល | ជាសមាជិក |
| - តំណាង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ជាសមាជិក |
| - តំណាង ក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| - តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| - តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| - តំណាង ក្រសួងកិច្ចការនារី | ជាសមាជិក |
| - តំណាង ក្រសួងអភិវឌ្ឍជនបទ | ជាសមាជិក |
| - តំណាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| - តំណាង ក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |

**មាត្រា ៥ .-**

**គ.ជ.ប.អ** មានបេសកកម្មដូចតទៅ ÷

- ធានាកិច្ចសហការ សំរបសំរួល ដ៏សមស្របក្នុងការអនុវត្ត គោលនយោបាយ និងកម្មវិធី ដែល ទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ

- ត្រួតពិនិត្យតាមដាន និង វាយតំលៃពីគោលនយោបាយ និងកម្មវិធីទាំងឡាយ ដែលទាក់ទង នឹង សេវាកម្មពន្យារកំណើត សុខភាពបន្តពូជ សន្តិសុខស្បៀង ការអភិវឌ្ឍធនធានមនុស្ស យេនឌ័រ និងការអភិវឌ្ឍ បរិស្ថាន ការរៀបចំដែនដី ការបំលាស់ទីលំនៅ ជីវភាពរស់នៅ ការអភិវឌ្ឍ ប្រកបដោយចីរភាព កិច្ចការពារ និងលើកកំពស់សុខមាលភាព និងការចូលរួមចំណែករបស់ប្រជាជន និងគោលនយោបាយផ្សេងៗទៀត ដែលទាក់ទងនឹងប្រជាជន និងការអភិវឌ្ឍ ។

**មាត្រា ៦.-**

**គ.ជ.ប.អ** ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង មានភារកិច្ចដូចតទៅ ÷

- ស្រាវជ្រាវ និងផ្សព្វផ្សាយពត៌មាន ស្តីពីសេចក្តីត្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងប្រជាជន ជូនទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពនានា
- សំរបសំរួល និងធ្វើសហប្រតិបត្តិការជាមួយនឹងក្រសួងពាក់ព័ន្ធ តំណាងភ្នាក់ងារអង្គការសហប្រជាជាតិជាពិសេសជាមួយនឹងអង្គការមូលនិធិសហប្រជាជាតិសំរាប់ប្រជាជន(UNFPA) អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន និងតំណាងវិទ្យាស្ថានស្រាវជ្រាវ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍ ដើម្បីធានានូវភាពរលូន និងភាពជាដៃគូក្នុងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល
- សំរបសំរួលជាមួយគណៈកម្មការនៃរដ្ឋសភា និងព្រឹទ្ធសភាក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងចូលរួមដឹកនាំសិក្ខាសាលា វគ្គបណ្តុះបណ្តាល សន្និសីទជាតិនិងអន្តរជាតិ ដើម្បីជាជំនួយក្នុងការសំរេចគោលដៅ កម្មវិធីនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ចងក្រង និងផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការ កម្មវិធី គោលនយោបាយ និងសេចក្តីប្រកាស ដែលទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍ
- ត្រួតពិនិត្យ និងកែសម្រួលគោលនយោបាយប្រជាជន និងយុទ្ធសាស្ត្រជាតិប្រជាជនអោយកាន់តែល្អប្រសើរ តាមការវិវត្តន៍ នៃសភាពការណ៍ក្នុងតំបន់ និងពិភពលោក
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងពត៌មានក្នុងការផ្សព្វផ្សាយនិងបញ្ចូលបញ្ហាប្រជាជននិងការអភិវឌ្ឍទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថាននានា
- ទទួលអនុវត្តការងារមួយចំនួនថែមទៀត ដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីប្រគល់ជូន

- ធ្វើរបាយការណ៍ ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារតាមកាលកំណត់អោយបានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល។

**មាត្រា ៧.-**

- **គ.ជ.ប.អ** មានអគ្គលេខាធិការដ្ឋានជាជំនួយការ និងមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប
- អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់
- អគ្គលេខាធិការរង មានឋានៈស្មើ អគ្គនាយក
- ផ្នែកជំនាញត្រូវដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន
- អគ្គលេខាធិការដ្ឋានអាចបង្កើតក្រុមជំនាញនៅតាមខេត្ត-ក្រុង ។

**មាត្រា ៨.-**

- **គ.ជ.ប.អ** ធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធាន
- **គ.ជ.ប.អ** ត្រូវប្រជុំជាសាមញ្ញរៀងរាល់មួយត្រីមាសម្តង និងអាចប្រជុំជាវិសាមញ្ញតាមការចាំបាច់
- ប្រធានអាចអញ្ជើញ អ្នកមានសមត្ថកិច្ចផ្សេងៗ នៃតំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ផ្នែកឯកជន តំណាងវិទ្យាស្ថានស្រាវជ្រាវពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស អ្នកផ្តល់ជំនួយ សង្គមស៊ីវិល អោយចូលមកបំភ្លឺ ចូលរួមកិច្ចប្រជុំការងារ រឺសិក្សាលើឯកសារពាក់ព័ន្ធ។

**មាត្រា ៩.-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ស្ថាប័ន **គ.ជ.ប.អ** នេះត្រូវកំនត់ដោយអនុក្រឹត្យ។

**មាត្រា ១០.-**

**គ.ជ.ប.អ** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងកញ្ចប់ថវិកានៃទីស្តីការគណៈរដ្ឋមន្ត្រី និងដោយជំនួយពី ប្រភពផ្សេងៗ។

**មាត្រា ១១ .-**

**គ.ជ.ប.អ** មានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងដំណើរការការងាររបស់ខ្លួន។

**មាត្រា ១២ .-**

ព្រះរាជក្រឹត្យលេខ នស / រកត / ០៨០១ / ២៧៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១៣ .-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តន៍អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ១៤ .-**

ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤

**ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាស់បន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

៣រស.០៨០៤.២៣៨

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខៈ ១៩៥ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាន្ត តាន់**